**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងថវិកានិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់វិធាន និងនីតិវិធីគោលនៃការគ្រប់គ្រងថវិកានិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ការគ្រប់គ្រងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

### ផ្នែកទី១

### ក្របខ័ណ្ឌទូទៅនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

**មាត្រា៤.-**

**គ្រឹះស្ថានសាធារណៈរដ្ឋបាល** គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលមានថវិកាស្វយ័ត និងត្រូវឆ្លុះបញ្ចាំងនូវគ្រប់ប្រភពចំណូល និងគ្រប់មុខសញ្ញាចំណាយ ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស។ ថវិកានេះ ត្រូវរៀបចំស្របតាមគោលបំណងគោលនយោបាយ ដែលត្រូវបានកំណត់ដោយក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស និងដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល និងស្របតាមផែនការយុទ្ធសាស្ត្រថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

**អាណាប័កដើមខ្សែ** នៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាអាណាព្យាបាលបច្ចេកទេស។

**អាណាប័កផ្ទេរសិទ្ធិ** នៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជានាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ថវិកាស្វយ័តរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល** សំដៅដល់ថវិកាដែលកញ្ចប់ចំណូល ចំណាយត្រូវបានអនុញ្ញាតឱ្យរៀបចំជាឧបសម្ព័ន្ធនៃថវិកាក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងដោយមានការប្រគល់សិទ្ធិ

អំណាច និងការទទួលខុសត្រូវក្នុងកម្រិតកំណត់មួយ ដោយលិខិតបទដ្ឋានពាក់ព័ន្ធក្នុងការគ្រប់គ្រង និងចាត់ចែងអនុវត្ត។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតនៅក្រោមក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ដែលអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំ និងអនុវត្តថវិកាឱ្យស្របតាមគោលការណ៍ និងការណែនាំអំពីថវិកាកម្មវិធី។

## ផ្នែកទី២
## ការរៀបចំថវិកា

**មាត្រា៥.-**

ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាផែនការចំណូលចំណាយ ដែលទទួលបានការអនុម័តប្រចាំឆ្នាំនីមួយៗរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនោះ។

**មាត្រា៦.-**

ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ។

ចំណូល និងចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ចំណូល និងចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិការដ្ឋ។ ចំពោះថវិកាដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ត្រូវគោរពតាមវិធាននៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ។

ចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមានចំណូលផ្ទាល់ ការឧបត្ថម្ភពីថវិការដ្ឋ និងចំណូលផ្សេងៗទៀត។

ចំណាយ ត្រូវឆ្លុះបញ្ចាំងនូវគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។

គ្រឹះស្ថានសាធារណៈរដ្ឋបាល មិនអាចបង្កើតលក្ខខណ្ឌ ដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧.-**

ដំណាក់កាលនៃការរៀបចំថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចខាងក្រោម÷

- នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យបានលម្អិត និងគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសពិនិត្យ និងសម្រេចមុនថ្ងៃទី០១ ខែកក្កដា
- យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា គម្រោងចំណូល ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស
- ក្នុងអំឡុងខែកក្កដា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អញ្ជើញតំណាងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងនាយកគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកពិភាក្សាកម្រិតជំនាញបច្ចេកទេសដើម្បីការពារគម្រោងថវិការបស់ខ្លួន។ ក្នុងអំឡុងពេលនៃកិច្ចពិភាក្សានេះ ត្រូវរំលេចឱ្យឃើញអំពីអតិរេក ឬឱនភាពនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងសំណើឧបត្ថម្ភធនពីថវិការដ្ឋ
- ក្នុងអំឡុងខែសីហា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អញ្ជើញតំណាងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងនាយកគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកពិភាក្សាកម្រិតថ្នាក់ដឹកនាំស្របតាមបទប្បញ្ញត្តិជាធរមាន
- នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីលទ្ធផលនៃការពិភាក្សាគម្រោងថវិកា រួចត្រូវចាត់ចែងរៀបចំកែសម្រួលគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនឡើងវិញស្របតាមលទ្ធផលដែលបានពិភាក្សាខាងលើ រួចត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសយ៉ាងយូរត្រឹមដំណាច់ខែវិច្ឆិកា។ គម្រោងថវិកានេះនឹងត្រូវកែសម្រួលបន្ថែមទៀតតាមការចាំបាច់ ក្នុងករណីដែលខ្លឹមសារនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលត្រូវបានអនុម័ត មានការផ្លាស់ប្តូរពាក់ព័ន្ធនឹងឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបានអនុម័ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសដាក់ឱ្យអនុវត្តថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា៨.-**

ក្នុងករណីដែលអាណាព្យាបាលបច្ចេកទេសជំទាស់លើគម្រោងថវិកាប្រចាំឆ្នាំ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ត្រូវផ្ញើជូនសេចក្តីជំទាស់នេះទៅនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីពិនិត្យ ផ្តល់ការបំភ្លឺ ឬ/និងកែតម្រូវតាមការចាំបាច់។ កិច្ចដំណើរការនេះ ត្រូវធ្វើឡើងស្របតាមប្រតិទិនការងារដែលមានចែងក្នុងមាត្រា៧។

**ផ្នែកទី៣**

**ការអនុវត្តថវិកា**

**មាត្រា៩.-**

ក្រោយពេលបានទទួលប្រកាស ស្តីពីការបែងចែកឥណទានថវិកាផ្ទៃក្នុងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ទេរថវិកាឧបត្ថម្ភកធន ដែលជាចំណែករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈអាណត្តិបើកប្រាក់ តាមសំណើរបស់នាយកគ្រឹះស្ថាន ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិក្នុងរយៈពេល១ត្រីមាសម្តង។

អាណាប័កដើមខ្សែ ត្រូវធ្វើប្រកាសប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូននាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីចាត់ចែងបញ្ជានិងជម្រះចំណូល និងធ្វើប្រតិបត្តិការចំណាយស្របតាមច្បាប់ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**មាត្រា១០.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល មានសិទ្ធិអំណាច និងទទួលខុសត្រូវលើការបញ្ជា និងជម្រះចំណូល។

គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបង់ចូលគណនីប្រាក់បញ្ញើ។ រាល់ការប្រមូល និងបង់ចំណូលចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គណនេយ្យករត្រូវធ្វើការកត់ត្រាចំណូលទៅតាមមាតិកាថវិកា រួចត្រូវរាយការណ៍ជូននាយកគ្រឹះស្ថាន និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ។

គណនេយ្យករ ត្រូវធ្វើការបូកសរុបចំណូល ដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលទទួលបាន និងបានបង់ទៅរតនាគារជាតិ រួចរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

**មាត្រា១១.-**

ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាកម្មវត្ថុនៃការឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលនោះ ដែលបានទទួលការតែងតាំងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នីតិវិធីអនុវត្តថវិកាលម្អិត នឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២.-**

ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការទិញ ការជួសជុល ការសាងសង់ និងការជួលសេវា ត្រូវអនុវត្តតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

**មាត្រា១៣.-**

ការផ្ទេរឥណទានថវិកាពីជំពូកមួយទៅជំពូកមួយ នៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយពីមានការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយមានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអាណាព្យាបាលបច្ចេកទេស។ ប្រកាសផ្ទេរឥណទាននេះ ត្រូវចម្លងជូនក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស។

ការផ្ទេរឥណទានថវិកានៅក្នុងជំពូកតែមួយនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការផ្ទេរឥណទានថវិកាកម្មវិធី សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដូចខាងក្រោម÷

- ការផ្ទេរឥណទានថវិកាពីកម្មវិធីមួយ ទៅកម្មវិធីមួយ
  - ពីជំពូកមួយទៅជំពូកមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ការផ្ទេរឥណទានថវិកាពីអនុកម្មវិធីមួយ ទៅអនុកម្មវិធីមួយក្នុងកម្មវិធីតែមួយ
  - ពីជំពូកមួយទៅជំពូកមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះ ត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- ការផ្ទេរឥណទានថវិកាពីចង្កោមសកម្មភាពមួយ ទៅចង្កោមសកម្មភាពមួយក្នុងអនុកម្មវិធីតែមួយ/ឬ នៅផ្ទៃក្នុងចង្កោមសកម្មភាពតែមួយ
  - ពីជំពូកមួយទៅជំពូកមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះ ត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាល់ការផ្ទេរឥណទានថវិកាត្រូវមានមូលដ្ឋាននៃការវិភាគច្បាស់លាស់ ដែលធានាថានឹងមិនធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារ គោលដៅយុទ្ធសាស្ត្រជាអាទិភាពរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក៏ដូចជាគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសដែលបានកំណត់។

**មាត្រា១៤.-**

កិច្ចប្រតិបត្តិការចំណាយថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលមាន ៤ ដំណាក់កាលសំខាន់ៗ÷

- ដំណាក់កាលធានាចំណាយ
- ដំណាក់កាលលទ្ធកម្មសាធារណៈ
- ដំណាក់កាលជម្រះបញ្ជី
- ដំណាក់កាលអាណត្តិកិច្ច និងទូទាត់។

**មាត្រា១៥.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលអាចយល់ព្រម ឬមិនយល់ព្រមផ្តល់ទិដ្ឋាការធានាចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុដែលមានចែងជាធរមាន។

ទិដ្ឋាការធានាចំណាយរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបញ្ជាក់អំពី÷

- កម្មវត្ថុចំណាយដែលស្របតាមមាតិកាថវិកា ក៏ដូចជាស្របតាមគម្រោងថវិកាដែលបានអនុម័ត និងធានាបាននូវប្រសិទ្ធភាពចំណាយ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- កំណត់ចំនួនទឹកប្រាក់ដែលត្រូវផ្តល់ទិដ្ឋាការចំណាយ
- ភាពទំនេរនៃឥណទាន និងស្ថានភាពប្រាក់បញ្ញើនៅរតនាគារជាតិ ដើម្បីជាមូលដ្ឋានពិចារណាលទ្ធភាពដែលអាចទូទាត់បាន។

**មាត្រា១៦.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវលើកិច្ចជម្រះបញ្ជី។

កិច្ចជម្រះបញ្ជីអាចធ្វើទៅបាន បន្ទាប់ពីការបញ្ចាទិញ កិច្ចសន្យាលទ្ធកម្មទិញ សំណង់ ឬសេវានានាត្រូវបានបំពេញរួចរាល់។

**មាត្រា១៧.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដោយឆ្លងការត្រួតពិនិត្យហិរញ្ញវត្ថុពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

អាណត្តិបើកប្រាក់ ដែលគ្មានទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ ឬមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គឺពុំអាចប្រើប្រាស់បានសម្រាប់ការទូទាត់ ឬដកប្រាក់ពីគណនីប្រាក់បញ្ញើនៅរតនាគារជាតិបានឡើយ។

រតនាគារជាតិ ត្រូវធ្វើការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជូនគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមរូបភាពបង្វែរ ឬមូលប្បទានបត្រ ក្រោយពីទទួលបានសំណើសុំដកប្រាក់ដោយភ្ជាប់ជាមួយអាណត្តិបើកប្រាក់ជាច្បាប់ថតចម្លង។

អាណត្តិបើកប្រាក់ និងសលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំ និងដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអភិបាលហិរញ្ញវត្ថុនៃថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុនេះ ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមការចាំបាច់។

**មាត្រា១៩.-**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានចែងក្នុងមាត្រា២៦ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ជាមន្ត្រីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុ ដែលត្រូវបានជ្រើសរើសជាសេនាធិការឱ្យនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែងតាំងដោយក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមគោលនយោបាយយុទ្ធសាស្ត្រ ដែលក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសបានកំណត់ និងផែនការសកម្មភាពរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល

- រៀបចំផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័នអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំការអនុវត្ត និងការត្រួតពិនិត្យថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

- គ្រប់គ្រង និងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន

- តាមដានលទ្ធផលនៃការអនុវត្តថវិកា

- សម្របសម្រួលក្នុងនាមជាសេនាធិការរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការតាមដាន ត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្ម។

**មាត្រា២០.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់លក្ខខណ្ឌនៃការរៀបចំ និងគំរូរបាយការណ៍ ដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ សម្រាប់ដាក់ឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលអនុវត្ត។

**មាត្រា២១.-**

ការបង្កើតរជ្ជទេយ្យចំណូល និង/ឬរជ្ជទេយ្យបុរេប្រទាន និងការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស បន្ទាប់ពីទទួលបានសំណើពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល។

កិច្ចបញ្ជិការជ្ជទេយ្យចំណូល និងរជ្ជទេយ្យបុរេប្រទាន ត្រូវអនុវត្តតាមប្រកាសស្តីពីកិច្ចបញ្ជិការជ្ជទេយ្យចំណូល និងប្រកាសស្តីពីកិច្ចបញ្ជិការជ្ជទេយ្យបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីចាំបាច់ដែលត្រូវស្នើសុំប្រាក់បុរេប្រទានសម្រាប់ចំណាយ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវសុំយោបល់ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។

**មាត្រា២២.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញគោលការណ៍ណែនាំលម្អិតពាក់ព័ន្ធនឹងអតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៣

## លទ្ធកម្មសាធារណៈ

**មាត្រា២៣.-**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា២៤.-**

កិច្ចលទ្ធកម្មសាធារណៈនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវដំណើរការប្រតិបត្តិតាមគោលការណ៍ វិធីសាស្ត្រ នីតិវិធីលទ្ធកម្មដូចគ្នាទៅនឹងការអនុវត្តនៅគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម។

**មាត្រា២៥.-**

កិច្ចលទ្ធកម្មរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវប្រតិបត្តិដោយអង្គភាពប្រតិបត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលគ្រប់គ្រង និងដឹកនាំអនុវត្តដោយគណៈកម្មាធិការលទ្ធកម្មមួយ ដែលមាននាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលជាប្រធាន និងមានអង្គភាពលទ្ធកម្មមួយជាលេខាធិការដ្ឋាន។ ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម។

**មាត្រា២៦.-**

គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ត្រូវបានសម្រេចបង្កើតដោយនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

**មាត្រា២៧.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម ដែលមានអង្គភាពលទ្ធកម្មជាសេនាធិការ ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ផែនការលទ្ធកម្មកែតម្រូវ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្តល់ការយល់ព្រម។

**មាត្រា២៨.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ឱ្យបានទៀងទាត់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា២៩.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមលក្ខខណ្ឌ កំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៣០.-**

ទ្រព្យសម្បត្តិរដ្ឋ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល តាមបែបបទ និងនីតិវិធី ដែលត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣១.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញគោលការណ៍ណែនាំលម្អិតអំពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៥
## កិច្ចបញ្ជិកាគណនេយ្យ

**មាត្រា៣២.-**

គោលការណ៍នៃកិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យសាធារណៈ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានប្លង់គណនេយ្យ ដែលដកស្រង់ពីប្លង់គណនេយ្យសាធារណៈ។ ប្លង់គណនេយ្យនេះមានការទទួលស្គាល់ និងយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន÷

- គណនេយ្យ ដែលគោរពតាមគោលការណ៍ទ្វេភាគ ដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការសាច់ប្រាក់ ប្រតិបត្តិការជាមួយតតិយជន និងកំណត់សំគាល់
- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

ការិយបរិច្ឆេទគណនេយ្យនីមួយៗ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់រយៈពេល១២(ដប់ពីរ) ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល។

ចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបង្កើតឡើងថ្មី ការិយបរិច្ឆេទទី១ ត្រូវគិតចាប់ពីកាលបរិច្ឆេទបង្កើតគ្រឹះស្ថាននោះជាផ្លូវការ រហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។

**មាត្រា៣៣.-**

គណនេយ្យករមានភារកិច្ចដូចខាងក្រោម÷

- គ្រប់គ្រងការប្រមូលចំណូល

- ទូទាត់ចំណាយ
- កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកលិខិតយុត្តិការជាច្បាប់ដើម
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

គណនេយ្យករ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដាក់ជូននាយក និងក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន-សាធារណៈរដ្ឋបាល ដើម្បីពិនិត្យ និងអនុម័ត និងបញ្ជូនទៅក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល មានកាតព្វកិច្ចរក្សាទុករាល់បញ្ជី និងឯកសារគណនេយ្យ ព្រមទាំងឯកសារ និងលិខិតយុត្តិការនានារបស់ខ្លួន ឱ្យបានគង់វង្សក្នុងរយៈពេលយ៉ាងតិច១០(ដប់)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការបង្កើតឯកសារទាំងនោះ។

## ជំពូកទី៦
## អធិការកិច្ច និងសវនកម្ម

**មាត្រា៣៤.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវលើការរៀបចំបង្កើត និងរក្សាឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព។

ភ្នាក់ងារសវនកម្មផ្ទៃក្នុង គឺត្រូវវាយតម្លៃដោយឯករាជ្យនូវអនុលោមភាព ភាពសមស្រប និងសមហេតុផលនៃកិច្ចប្រតិបត្តិការទាំងឡាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងស័ក្តិសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ផែនការ និងរបាយការណ៍សវនកម្មផ្ទៃក្នុង ត្រូវផ្ញើជូនក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលទាំងពីរ។

**មាត្រា៣៥.-**

ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាកម្មវត្ថុនៃការធ្វើអធិការ-កិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**មាត្រា៣៦.-**

មន្ត្រីរាជការពាក់ព័ន្ធគ្រប់ប្រភេទ និងគ្រប់ឋានៈ ដែលមិនបានគោរពការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនមិនបានត្រឹមត្រូវពាក់ព័ន្ធនឹងប្រាក់កាសសាធារណៈ ដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៨._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

<u>**កន្លែងទទួល÷**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ